# សិទ្ធិ និងឯកជនភាពនៃឧបករណ៍វាយតម្លៃ CALWORKS អនឡាញ
# (ONLINE CALWORKS APPRAISAL TOOL RIGHTS AND PRIVACY)

នេះជាទិដ្ឋភាពទូទៅនៃដំណើរការឧបករណ៍វាយតម្លៃ CalWORKs អនឡាញ ( Online CalWORKs Appraisal Tool, OCAT )

បុគ្គលិកគ្រប់គ្រងសំណុំរឿងរបស់អ្នកនឹងសួរសំណួរជាច្រើនអំពីភាពខ្លាំង អត្ថប្រយោជន៍ និងប្រវត្តិ សិក្សារបស់អ្នក។ ការធ្វើបែបនេះនឹងជួយកំណត់អត្តសញ្ញាណកត្តាណាមួយក្នុងជីវិតរបស់អ្នកដែលអាចធ្វើឲ្យអ្នកពិបាកក្នុងការផ្តោតលើការងារ ឬសកម្មភាពដែលទាក់ទងនឹងការងារ។

គោលបំណងរបស់ Welfare-to-Work គឺដើម្បីឲ្យអ្នកទទួលបានជំនាញ និងជួយអ្នកបំពេញតម្រូវការរបស់អ្នក ដូច្នេះអ្នកអាចស្វែងរកការងារ និងក្លាយជា អ្នកដែលចេះម្ចាស់ការលើខ្លួនឯងបាន។

ការសម្ភាសន៍នឹងចំណាយពេលប្រហែលមួយម៉ោងទៅមួយម៉ោងកន្លះដើម្បីបញ្ចប់។ សំណួរនានានឹងជួយបុគ្គលិកគ្រប់គ្រងសំណុំរឿងរបស់អ្នកស្វែងរកនូវសេវា និងសកម្មភាពអ្វីដែលអ្នកត្រូវការក្នុងពេលនេះ។

អ្នកនឹងត្រូវបានសួរសំណួរលើប្រធានបទដូចខាងក្រោម៖
- ព័ត៌មានទូទៅ មានដូចជាអ្នកដែលរស់នៅជាមួយអ្នក
- ប្រវត្តិការងារ
- ប្រវត្តិសិក្សា
- សុខភាពរាងកាយ ផ្លូវចិត្ត និងអារម្មណ៍របស់អ្នក និងគ្រួសាររបស់អ្នក
- ការបារម្ភអំពីការធ្វើដំណើរ និងកន្លែងស្នាក់នៅ
- ការបារម្ភអំពីការរំលោភបំពានក្នុងគ្រួសារ និងសុវត្ថិភាព
- ការបារម្ភអំពីការសេពគ្រឿងញៀន ឬជាតិអាកុល

ត្រូវចងចាំក្នុងចិត្តអំឡុងពេលសម្ភាសន៍៖
- សំណួរខ្លះៗអាចនឹងធ្វើឲ្យមានអារម្មណ៍មិនស្រួល ប៉ុន្តែពួកវានឹងត្រូវបានសួរសំណួរដើម្បីឲ្យកាន់តែយល់ច្បាស់នូវអ្វីដែលអាចជួយបំពេញតម្រូវការរបស់អ្នកដើម្បីទទួលបានការងារ។
- អ្វីៗដែលបានពិភាក្សាក្នុងពេលសម្ភាសន៍គឺជាការសម្ងាត់។ នេះមានន័យថាបុគ្គលិកគ្រប់គ្រងសំណុំរឿងរបស់អ្នកនឹងរក្សាទុកនូវអ្វីៗដែលអ្នកនិយាយអំពីឲ្យជាសម្ងាត់។ ករណីតែមួយគត់ដែលបុគ្គលិកគ្រប់គ្រងសំណុំរឿងរបស់អ្នកនឹងមិនរក្សាការសម្ភាសន៍ជាសម្ងាត់ គឺប្រសិនបើចម្លើយរបស់អ្នកហាក់បីដូចជាមានការរំលោភបំពាន ឬការមិនយកចិត្តទុកដាក់ចំពោះមនុស្សចាស់ ឬកុមារកំពុងកើតឡើងប៉ុណ្ណោះ។ បុគ្គលិកពាក់ព័ន្ធនឹងសំណុំរឿងរបស់អ្នកតម្រូវឲ្យរាយការណ៍អំពីការរំលោភបំពានលើមនុស្សចាស់ ឬកុមារដែលគួរសង្ស័យដើម្បីធ្វើការស៊ើបអង្កេត។
- មនុស្សដែលមានពិការភាពមានសិទ្ធិទទួលបានជំនួយពិសេសនានាដែលពួកគេអាចត្រូវការ។ ប្រសិនបើអ្នកត្រូវការជំនួយពិសេសអំឡុងពេលសម្ភាសន៍នេះ សូមប្រាប់បុគ្គលិកគ្រប់គ្រងសំណុំរឿងរបស់អ្នក។
- ការសម្ភាសន៍មានសំណួរផ្ទាល់ខ្លួនជាច្រើនដែលត្រូវការចាំបាច់ដើម្បីស្វែងរកជំណាក់កាលបន្ទាប់ក្នុងដំណើរការសម្រាប់អ្នក។ អ្នកនឹងមិនត្រូវបានដាក់ពិន័យទេ ប្រសិនបើអ្នកមិនចង់ឆ្លើយសំណួរ។

សូមប្រាប់បុគ្គលិកគ្រប់គ្រងសំណុំរឿងរបស់អ្នក ប្រសិនបើនៅពេលណាមួយនៃដំណើរការនេះ អ្នកមានសំណួរណាមួយអំពីថាតើសំណួរអ្វីដែលគេនឹងសួរអ្នក ឬអំពីដំណើរការ OCAT។

---

**ការទទួលស្គាល់របស់អ្នកចូលរួម៖**

**ខ្ញុំបានអានទម្រង់នេះ ឬគេបានអានទម្រង់នេះឲ្យខ្ញុំស្តាប់។**

**ខ្ញុំយល់ពីចំណុចដូចខាងក្រោម៖**
- **ហេតុអ្វីយើងត្រូវធ្វើការសម្ភាសន៍នេះ។**
- **ព័ត៌មានដែលខ្ញុំផ្តល់ឲ្យនឹងត្រូវបានរក្សាការសម្ងាត់ លុះត្រាតែមានការរំលោភបំពានលើមនុស្សចាស់ ឬកុមារដែលគួរឲ្យសង្ស័យ។**

____________________________ ______________

(ហត្ថលេខារបស់អ្នកចូលរួម) (កាលបរិច្ឆេទ)